Page Liked · Yesterday ·

*ដោយ សួន សេរីរដ្ឋា*

នៅស្រុកខ្មែរ មានអ្នកនយោបាយ ស៊ីខ្មោច ! ថ្ងៃនេះខ្ញុំនិទានរឿងខ្លីមួយ ជូនដូចតទៅ ៖

អាចារ្យសុខ គាត់ជាអាចារ្យបុណ្យខ្មោច ។ ហើយតាមធម្មតាឲ្យតែមានខ្មោចស្លាប់ក្នុងភូមិ គឺគាត់មានមុខ កាន់ក្បាលមេក្រូរហូតដល់ចប់បុណ្យ ។ ដូច្នោះហើយរាល់ ពេល ឲ្យតែឮថាផ្ទះណា គ្រួសារណា មានទុក្ខដោយសមាជិកគ្រួសារស្លាប់ គឺមិនចាំបាច់មានអ្នកមកអញ្ជើញគាត់ទេ គឺគាត់រៀបចំប្រដាប់ប្រដា សម្រាប់ពិធីបុណ្យខ្មោចដាក់កង់របស់គាត់ ហើយចេញដំណើរទៅដល់ផ្ទះ គ្រួសារអ្នកមានទុក្ខ ។

ថ្ងៃនេះលោកអាចារ្យ សុខ គាត់ទទួលដំណឹងថា កូនចៅអ្នកស្រុកភូមិរបស់គាត់ ដែលធ្វើការនៅឯភ្នំពេញនោះ ត្រូវគេបាញ់សម្លាប់ ។ គាត់ក៏រៀបចំសម្ភារៈរបស់គាត់ សម្រាប់បុណ្យខ្មោច ឡើងកង់រឹងទៅដល់ផ្ទះអ្នកស្រុកគ្រួសារដែលមានទុក្ខនោះ ដូចគាត់បានធ្វើទៅជួយយកអាសារអ្នកភូមិស្រុកផ្សេងៗទៀតដែរ ។ លុះទៅដល់ មិនឃើញសាច់ញាត្តិសព នៅផ្ទះរៀបចំបុណ្យសព គាត់ក៏សួរអ្នកជិតខាង ហើយអ្នកជិតខាងប្រាប់លោកអាចារ្យថា ៖ អ្នកស្លាប់មានមិត្តភក្តិច្រើន និងអ្នកស្គាល់ច្រើននៅភ្នំពេញ ដូចនេះសាច់ញាត្តិ មិនទាន់យកសពមកស្រុកកំណើតទេ នៅធ្វើបុណ្យឲ្យមិត្តភក្តិ អ្នកស្គាល់បានចូលរួមគោរពសិន ហើយ ១ អាទិត្យទៀតបានដង្ហែសពមក ។

អាចារ្យ សុខ គាត់ស្តាប់ហើយក៏លាត្រឡប់មកផ្ទះវិញ ។

មួយអាទិត្យក្រោយ គាត់ក្រោកពីព្រលឹមរៀបចំគ្រឿងប្រដាប់អាចារ្យរបស់គាត់ ដាក់កង់ ឡើងជិះរឹងទៅ ផ្ទះគ្រួសារអ្នកស្លាប់ម្តងទៀត ។ លុះទៅដល់ គាត់ឃើញផ្ទះស្ងាត់ដដែល និងមិនឃើញគ្រួសារ សាច់ញាត្តិសពរៀបចំធ្វើអីសោះនៅផ្ទះ ។ គាត់មិនអស់ចិត្ត នឹកថាប្រហែលខ្លួនមកមុនពេល ក៏សុខចិត្តអង្គុយចាំនៅមុខផ្ទះ ។ បន្តិចក្រោយមកមានអ្នកស្រុក ជិះរ៉ឺម៉ក មកពីភ្នំពេញចុះនៅផ្ទះជិតនោះ ។ អ្នកស្រុកនោះ គាត់ក្រឡេកឃើញលោកអាចារ្យ សុខ ក៏ស្រែកសួរ ៖ លោកអាចារ្យ មកអង្គុយធ្វើអីទីនេះ ?

អាចារ្យ សុខ ឆ្លើយ ៖ ខ្ញុំ មកចាំជួយធ្វើអាចារ្យបុណ្យខ្មោច អ្នកស្រុកយើង ព្រោះឮគេថាហែមកស្រុកកំណើតថ្ងៃនេះ ។

អ្នកស្រុក ៖ ណ្ហើយ លោកតាអាចារ្យ សុខ អើយ ! មើលទៅលោកតាអាចារ្យ ឯងមិនមានវាសនាបានធ្វើជាអាចារ្យបុណ្យសពគាត់ទេ ពីព្រោះសពគាត់នៅភ្នំពេញ ពួកអ្នកនយោបាយ កំពុងហែកស៊ី ! ??? ។

លោកអាចារ្យ សុខ ឮដូច្នោះ ស្ទុះភ្លែតទៅចាប់ចង្កូតកង់ ទាញបង្វិលកង ធាក់រឹងបកមកផ្ទះវិញ... តែតាមផ្លូវ គាត់គិតតែពីគ្រវីក្បាលឆ្ងល់ម្នាក់ឯងថា ៖ ហេតុអី ក៏អ្នកនយោបាយ ស៊ីខ្មោច ? ក្រែងអ្នកនយោបាយ សុទ្ធតែជាបុគ្គល

អ្នកសិក្សារៀនសូត្រ ហើយថ្លៃថ្នូរ ? ម្ដេចក៏មកស៊ីខ្មោច ដូចត្មាត ? អាចារ្យ សុខ គាត់មកដល់ផ្ទះហើយ គាត់នៅតែគិតមិនយល់ពីបញ្ហា អ្នកនយោបាយស៊ីខ្មោចនោះទៀត ។ គាត់អង្គុយរហូតភ្លឹក ដល់កូនស្រីគាត់មកពីក្រៅសួរគាត់ថា ៖ ពុក ក្រែងពុក ទៅធ្វើអាចារ្យបុណ្យសពគេ នៅចុងភូមិ ហី ម៉េចប្រញ៉ាប់មកវិញម្លេះ ?

អាចារ្យ សុខ ឆ្លើយ ៖ មីនាង ឯងដែលដឹងទេ គេថា អ្នកនយោបាយ ហែក ខ្មោចស៊ី ? វាស៊ី មែនឬមីនាង ?

កូនស្រី អាចារ្យ សុខ ៖ ហឺយ... ពុកអើយពុក ឲ្យតែអ្នកល្បីៗត្រូវគេសម្លាប់នោះ គេហែកសាច់ចែកគ្នាស៊ីអស់ហើយ បានសល់ឆ្អឹងគេយកមកឲ្យពុក ! ។

អាចារ្យ សុខ ៖ លើកដៃ គ្រវី និយាយញ័រមាត់... ទេៗ មីនាង ឪ ធ្វើអាចារ្យខ្មោចមែន តែចំណាស់នេះហើយ ឪមិនដែលស៊ីខ្មោចទេ មិនថាសាច់ ឬឆ្អឹង ឪមិនស៊ីទេខ្មោចទេណា ! ។ និយាយរួច តាសុខ ចូលទៅដេកទទូភួយ ហើយអារម្មណ៍ គាត់គឺជិតជាប់ខ្លាចអ្នកនយោបាយស៊ីខ្មោច ។ ស្រុកខ្មែរ ពិតជាអ្វីក៏មានមែន ៕